រឿង

# មិត្តភាពរវាងកុមារ និង សត្វដំរី



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

មន្ទីរអប់រំយុវជន និង កីឡា

ខេត្ត កោះកុង

លេខ:.................អយក.ខកក

**ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តកោះកុង**

**សូមគោរពជូន**

**លោកប្រធានអង្គការម្លប់បៃតង**

-កម្មវត្ថុ: យល់ព្រមអនុញ្ញាត ឱ្យបោះពុម្ពផ្សាយសៀវភៅ រឿង មិត្តភាពរវាងកុមារ និង សត្វដំរី

-យោង: កិច្ចព្រមព្រៀងគម្រោងការរវាង ក្រសួងអប់រំយុវជន និង កីឡា នៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ( WILDLIFE ALLIANCE)

លោកប្រធានអង្គការម្លប់បៃតងជាទីគោរព គម្រោងអប់រំបរិស្ថានចល័តគឺជាកម្មវិធីមួយ ដែលធ្វើសកម្មភាពក្រោមការសហការរវាង អង្គការសម្ព័ន្ធមិត្តសត្វព្រៃ **Wildlife Alliance** និង មន្ទីរអប់រំយុវជន និង កីឡាខេត្ត កោះកុង របស់ក្រសួងអប់រំយុវជន និង កីឡា តាំងពីឆ្នាំ ២០០៤មក ។

ដោយឆ្លងតាមការពិនិត្យយ៉ាងត្រឹមត្រូវលើខ្លឹមសាសៀវភៅរឿង មិត្តភាពរវាងកុមារ និង សត្វដំរីនេះ ខ្ញុំបាទសូមធ្វើការអនុញ្ញាតឱ្យបោះពុម្ពសៀវភៅដែលបានជម្រាបជូនខាងលើដើម្បីឱ្យក្រុមការងាររបស់អង្គការសម្ព័ន្ធមិត្ត សត្វព្រៃបាន យកសៀវភៅនេះទៅធ្វើការអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សនៅតាមសាលាបឋមសិក្សា និង សហគមន៍ នានា ក្នុងខេត្តកោះកុង ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានអង្គការទទួលយកនូវការអនុញ្ញាតពីខ្ញុំបាទតាមការគួរ

សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំបាទ ។

កោះកុង ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៨

**ប្រធានមន្ទីរ**

**ស្វន សីហា**

រក្សាសិទ្ធិគ្រប់យ៉ាងដោយៈ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ ( Wildlife Alliance)

រឿង

# មិត្តភាពរវាង កុមារ និង សត្វដំរី





កាលដើមឡើយ មានសហគមន៍មួយនៅក្បែរ
តំបន់ដែនជម្រកសត្វព្រៃ នៃប្រទេសកម្ពុជា។



ថ្ងៃមួយ នៅពេលដែលកុមារា និងកុមារីមួយក្រុមតូចដើរលេងនៅក្នុងព្រៃខាងក្រោយសហគមន៍ ស្រាប់តែពួកគេប្រទះឃើញអាចម៍សត្វធំៗ។ ប៉ុន្តែពួកគេមិនស្គាល់ថាជាអាចម៍សត្វអ្វី ក៏សួរគ្នាដូច្នេះថា:






ដំរីជាសត្វដីគោកដ៏ធំជាងគេនៅក្នុងលោក។ សត្វដំរីមួយក្បាលអាចមានទម្ងន់ពី ៣.៥០០-៥.០០០ គីឡូក្រាម។ អ្នកអាចរំពឹងមើលថាសត្វដ៏ធំបែបនេះត្រូវការស៊ីច្រើនណាស់។ សត្វដំរីអាចស៊ីស្មៅ ស្លឹកឈើ ផ្លែឈើ សំបកឈើ និងរុក្ខជាតិដ៏ទៃទៀត ប្រមាណ ២០០គ.ក ក្នុងមួយថ្ងៃ។


កុមារីដានីនិយាយៈ
បើអញ្ចឹងពួកយើងនាំគ្នាតាមមើលទៅ ក្រែងឃើញ តើវាធំប៉ុណ្ណា ?
ក្មេងៗទាំងអស់និយាយៈ
-តោះ តោះៗពួកយើងទាំងអស់គ្នា! ទៅ
កុមារាសំនិយាយៈ
នែ៎ពួកយើងនោះន៎! ឃើញហើយៗ នោះ! គឺជាសត្វដំរីទេតើ !
ក្មេងៗទាំងអស់និយាយៈ
មែនហើយៗៗៗ!



គេហៅសត្វដំរីមួយក្រុមថាសត្វដំរីមួយហ្វូង ។ សត្វដំរីមួយហ្វូងអាចមានចំនួនពី ៦-៤០ក្បាល ។ គេហៅសត្វដំរីមេដែលចាស់ជាងគេនៅក្នុងហ្វូងថាជាមេហ្វូង ។ មេហ្វូងជាអ្នកសម្រេចថាពេលណាឬកន្លែងណាដែលហ្វូងត្រូវផ្លាស់ប្តូរទីលំនៅ ។ សត្វដំរីឯទៀតនៅក្នុងហ្វូង ធ្វើតាមការដឹកនាំរបស់មេហ្វូង ។

ក្មេងៗទាំងអស់គ្នារវល់តែសប្បាយចិត្តដោយបានឃើញហ្វូងសត្វដំរី ភ្លេចខ្លួនទៅកាន់តែឆ្ងាយ ។ ពួកគេទាំងអស់គ្នាក៏វង្វេងនៅក្នុងព្រៃ ។ ពួកគេភ័យខ្លាំងណាស់ហើយនិយាយគ្នាដូច្នេះថា៖






សត្វដំរីអាចស្តាប់សំឡេងក្រោមកម្រិតដែលមនុស្ស
អាចស្តាប់បាន ហើយអាចស្តាប់ឮសំឡេងសត្វដំរី
ដ៏ទៃនៅទីដ៏ឆ្ងាយទៀតផង ។

សត្វដំរីបក់ត្រចៀករបស់វាដូចផ្លិតដើម្បីជួយធ្វើ
ឱ្យត្រជាក់ខ្លួននៅពេលថ្ងៃក្តៅ ។

រំពេចនោះកូនសត្វដំរីក៏បានឮ ហើយនាំគ្នាដើរចូលមកជិតក្មេងៗ រួចនិយាយថាៈ






ប្រមោយរបស់សត្វដំរីគឺជាច្រមុះដ៏វែង មាន ប្រវែងរហូតដល់២ម៉ែត្រ និងមានទម្ងន់ប្រហែលជា១៨០គីឡូក្រាម។ ក្រៅពីដកដង្ហើម និងស្រង់ក្លិន ប្រមោយអាចបំពេញតួនាទីដ៏អស្ចារ្យច្រើនទៀត។ សត្វដំរីប្រើប្រមោយសម្រាប់ចាប់យកអាហារ បូមទឹកដាក់មាត់ ព្រមទាំងអាចបញ្ចេញសំឡេងយ៉ាងខ្លាំង និងបង្ហាញនូវក្តីអាណិតស្រឡាញ់ដល់គ្នាវាផ្សេងទៀត។ ប្រមោយអាចផ្ទុកទឹកបានចំនួន៦លីត្រ និងអាចប្រើប្រាស់ដូចជាទុយោទឹកដែលទន់ អាចបត់បែនបានទៀតផង។


សូមសម្លាញ់ទាំងអស់គ្នាដើរតាមខ្ញុំមក
ខ្ញុំនឹងនាំដើរមើលទេសភាពក្នុងព្រៃ ហើយម្ដាយរបស់ខ្ញុំ
នឹងជូនសម្លាញ់ ត្រឡប់ទៅផ្ទះវិញ។



ហ្វូងសត្វដំរីក៏បាននាំកុមារទាំងអស់
ត្រឡប់មកដល់សហគមន៍របស់ពួកគេវិញ ។



ពួកសត្វដំរីក៏ដូចជាមនុស្សដែរ ត្រូវការបង្កាត់ពូជជាមួយសមាជិកនៃក្រុមគ្រួសារដំរីដទៃទៀត ។ នៅពេលដែលសត្វដំរីផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ពួកវាត្រូវតែរកសត្វដំរីពីគ្រួសារដទៃ ។ គឺតាមមធ្យោបាយនេះហើយ ដែលសត្វដំរីអាចបន្តពូជបាន ។

ពួកហ្វូងសត្វដំរីបាននាំកុមារា កុមារីមកដល់សហគមន៍ ដោយសុវត្ថិភាព រួចហើយលាគ្នាទៅវិញទៅមកដោយ ក្ដីអាឡោះអាល័យជាទីបំផុត ។





សត្វដីរត្រូវការតំបន់ធំទូលាយដើម្បីរស់នៅ ហើយត្រូវការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត ។ ជួនកាល ពួកវាត្រូវការឆ្លងកាត់ផ្លូវថ្នល់ ឬចំការដំណាំ ។ គឺនៅពេលនោះហើយដែលពួកវាអាចជួបប្រទះនឹងគ្រោះថ្នាក់ ។ ប្រសិនបើតំបន់ព្រៃភ្នំនានាត្រូវបានភ្ជាប់គ្នាដោយជាយព្រៃ នោះពពួកសត្វដីរអាចនឹងធ្វើដំណើរពីតំបន់មួយទៅតំបន់មួយទៀតដោយមិនជួបប្រទះនឹងគ្រោះថ្នាក់ឡើយ ។


ពេលវេលាបានកន្លងទៅអស់មួយរយៈ ..........
កូនសត្វដំរីនឹកដល់កុមារា កុមារី
ដែលជាសម្លាញ់របស់ពួកគេ
ហើយពួកសត្វដំរីក៏នាំគ្នាមកក្បែរ
សហគមន៍ ប៉ុន្តែបែរជាបានជួប
នឹងព្រានព្រៃទៅវិញ ។
ពួកយើង! នាំគ្នាបាញ់
សម្លាប់ហ្វូងសត្វដំរីទាំងនោះទៅ
ឱ្យលឿនឡើង! ៗៗ
គាប់ជួនពេលនោះពួកកុមារា កុមារីក៏មកទាន់
ហើយនាំគ្នាស្រែកឃាត់ពួកព្រានព្រៃខ្លាំងៗថា:
កុមារាសុខនិយាយ:
កុំ! ៗៗសម្លាប់ពួកសត្វដំរីទាំងនេះអីខ្ញុំសូមអង្វរៗៗ
ព្រោះពួកគេជាសម្លាញ់ខ្ញុំទេ  ពួកគេមកទីនេះ
គឺដើម្បីមកលេងនឹងពួកខ្ញុំទេ (កុំសម្លាប់ពួកគេអីៗៗ)
ម្យ៉ាងវិញទៀតខ្ញុំឮលោកយាយខ្ញុំប្រាប់ថា ដំរីជាសត្វ
ដែលកម្រ និងជិតផុតពូជអស់ពីប្រទេសកម្ពុជាយើង
ទៀតផង !




ដំរីជាសត្វដែលយកចិត្តទុកដាក់ចំពោះកូនតូចៗខ្លាំងណាស់ ។ ដំរីពេញវ័យតែងតែពាំងខ្លួនការពារកូនតូចៗ ទោះជាមានការគំរាមកំហែងណាមួយក៏ដោយ ។ ដំរីពេញវ័យខ្លះនឹងវាយប្រហារទៅលើព្រានប្រមាញ់ ឬសត្រូវ ដើម្បីកុំឱ្យគេធ្វើបាបក្រុមគ្រួសាររបស់វា ។


កុមារាសំនិយាយៈ ចំណែកខ្ញុំក៏នៅចាំសម្ដីលោកគ្រូអ្នកគ្រូធ្លាប់ប្រាប់ថា បើអ្នកណាសម្លាប់សត្វដែលកម្រក្នុងប្រទេសកម្ពុជាយើង ពិសេសគឺសត្វដំរី អ្នកនោះនឹងត្រូវទទួលទោសតាមច្បាប់ទៀតផងណា៎! លោកពូព្រានព្រៃ។ ដូច្នេះសូមកុំសម្លាប់ពួកសត្វដំរីទាំងនេះអី ពួកខ្ញុំទាំងអស់គ្នាសូមអង្វរ។




មានសត្វដំរីប្រមាណជាង ២០០.០០០ក្បាល ត្រូវបានគេយកមកប្រើប្រាស់ជាជំនួយក្នុងការកសាងអាណាចក្រអង្គរ ។

សូមអ្នកស្រមៃមើលថាតើមានសត្វដំរីប៉ុន្មានក្បាលដែលរស់នៅក្នុងព្រៃនាសម័យនោះ ហើយឥឡូវនេះមានសត្វដំរីប្រមាណតែ ២០០ក្បាលប៉ុណ្ណោះនៅក្នុងប្រទេសកម្ពុជា ។

ប្រសិនបើយើងមិនជួយពួកវាឥឡូវនេះទេសត្វដំរីនឹងបាត់បង់ជារៀងរហូតពីប្រទេសកម្ពុជាយើង ។

ថៃ្ងដន្យពេលនោះចាស់ៗព្រឹទ្ធាចារ្យក្នុងសហគមន៍ធ្វើដំណើរត្រឡប់មកពីវត្តវិញ កាត់តាមទីនោះ ក៏បានជួបព្រឹត្តិការណ៍យ៉ាងដូច្នេះ ហើយបានសួរនាំដឹងរឿងរ៉ាវសព្វគ្រប់ ពួកគាត់ក៏បានជួយពន្យល់បន្ថែមយ៉ាងច្រើន អំពីសារប្រយោជន៍នៃសត្វព្រៃ និងធនធានធម្មជាតិ ជាពិសេសគឺដំរីដែលជាសត្វកម្រ និងស្ទើរតែបាត់បង់អស់ទៅហើយ ។

<u>ព្រានព្រៃនិយាយៈ</u>

ស្តាប់ទៅសមហេតុផលមែន ។ នែ៎! ពួកយើងតើឯងគិតយ៉ាងណាដែរ ?
ខ្ញុំគិតថាពួកយើងកុំសម្លាប់សត្វដំរីនេះអី ពីព្រោះពួកវាគឺពិតជាសត្វដ៏មានសារប្រយោជន៍មែន ! យើងខ្ញុំបានយល់ដឹងច្រើន ហើយសន្យាថានឹងជួយចូលរួមថែរក្សាទាំងអស់គ្នាចាប់ពីពេលនេះតទៅ ។
ពួកខ្ញុំទាំងអស់គ្នាសូមអរគុណដល់លោកអ៊ុំ និងក្មួយៗហើយ!
ពួកខ្ញុំគិតសុំលាអ៊ុំៗ និងក្មួយៗសិនហើយ ។



សូមយើងទាំងអស់គ្នាចូលរួមចំណែកថែរក្សាការពារ និងអភិរក្សទាំងសត្វព្រៃ និងធនធានធម្មជាតិដែលជាទីជម្រករបស់ពួកវាកុំឱ្យដាច់ពូជ ដើម្បីទុកជាមរតកសម្រាប់កូនចៅជំនាន់ក្រោយៗផង ។



ការប្រមាញ់សត្វដំរី រួមទាំងពពួកពូជសត្វដែលកំពុងរងគ្រោះជិតផុតពូជទាំងអស់ត្រូវបានហាមឃាត់ផងដែរ ។ ការប្រមាញ់យកភ្លុកដំរីគឺជាអំពើគំរាមកំហែងមួយដ៏ធំចំពោះសត្វដំរីនៅក្នុងប្រទេសកម្ពុជា ដូចគ្នានឹងការបាត់បង់បរិស្ថានរស់នៅរបស់វាដែរ ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះ ការសម្លាប់សត្វដំរីមិនគ្រាន់តែជាទង្វើគួរឱ្យអៀនខ្មាស់ប៉ុណ្ណោះទេ ក៏ប៉ុន្តែវាជាអំពើមួយខុសច្បាប់ទាំងស្រុងទៀតផង ។

សត្វដំរីបានចូលមកជិតពួកក្មេងៗ ដោយទឹកមុខសប្បាយរីករាយ ។




កូនសត្វដំរីនិយាយៈ
មែនហើយ! បើគ្មានពួកសម្លាញ់ឯងទាំងអស់គ្នាទេម្ល៉េះពួកសត្វដំរីខ្ញុំ
នឹងបាត់បង់សមាជិកជាមិនខាន។ សម្លាញ់គឺជាអ្នកមានគុណរបស់
ពួកសត្វដំរីយើងទាំងអស់គ្នា។ ពួកសត្វដំរីខ្ញុំទាំងអស់មិនភ្លេចគុណ
សម្លាញ់ឡើយ  ពួកយើងសូមលាសម្លាញ់ទាំងអស់គ្នាសិនហើយ
(លាសិនហើយ    សូមឱ្យមានសេចក្ដីសុខសប្បាយណា៎!)

# សំណួររំលឹកមេរៀន

១. តើកុមារា និងកុមារី ប្រទះឃើញអាចម៍សត្វអ្វី?

២. តើអាចម៍សត្វដែលកុមារា និងកុមារីឃើញនោះ តូចៗ ឬធំៗ?

៣. ពេលឃើញអាចម៍សត្វភ្លាម តើកុមារា និងកុមារី ស្គាល់ឬទេ?

៤. នៅពេលដែលកុមារា កុមារីវង្វេងក្នុងព្រៃ តើពួកគេបានជួបនឹងនរណាមុនគេ? ចុះបន្ទាប់មក ពួកគេធ្វើអ្វីខ្លះទៀត?

៥. តើកូនសត្វដំរីសុំកុមារា កុមារីទាំងអស់នោះធ្វើជាអ្វីនឹងគ្នា?

៦. នៅពេលដែលកូនដំរី និងក្មេងៗក្លាយជាមិត្តល្អនឹងគ្នា តើពួកគេសប្បាយចិត្តឬទេ? តើនរណាជាអ្នកជូនពួកគេត្រឡប់មកសហគមន៍វិញ?

៧. តើសត្វដំរីជួបឧបសគ្គអ្វីនៅពេលដែលពួកគេមកលេងកុមារា កុមារី?

៨. តើព្រានព្រៃបម្រុងធ្វើអ្វី ទៅលើហ្វូងសត្វដំរីទាំងនោះ?

៩. តើកុមារា កុមារីឃាត់ពួកព្រានព្រៃ កុំឱ្យសម្លាប់សត្វដំរីដែរឬទេ? ព្រោះអ្វី?

១០.តើមាននរណាផ្សេងទៀតបានមកជួបក្មេងៗ សត្វដំរី និងព្រានព្រៃដែរឬទេ? តើពួកគាត់បានពន្យល់អ្វីខ្លះដល់ព្រានព្រៃ។

១១. តើពួកព្រានព្រៃគិតយ៉ាងណាដែរ នៅពេលក្មេងៗ និងចាស់ព្រឹទ្ធាចារ្យព្យាយាមពន្យល់ដល់ពួកគាត់?

១២. តើហ្វូងសត្វដំរីថ្លែងអំណរគុណដល់ក្មេងៗ និងចាស់ៗព្រឹទ្ធាចារ្យទាំងនោះឬទេ? ព្រោះអ្វី ?

១៣. ប្រសិនបើគ្មានពួកកុមារា កុមារីទាំងនោះទេ តើព្រានព្រៃសម្លាប់សត្វដំរីឬទេ?

អង្គការសម្ព័ន្ធមិត្តសត្វព្រៃ ( **WILDLIFE ALLIANCE**) សូមថ្លែងអំណរគុណដល់អង្គការ **USFWS & IEF** ដែលបានឧបត្ថម្ភថវិកា ក្នុងការបោះពុម្ពសៀវភៅនេះ និងសូមថ្លែងអំណរគុណដល់អង្គការម្លប់បៃតងដែលបានសហការរៀបចំបោះពុម្ព ព្រមទាំងវិចិត្រករដែលបានលម្អសៀវភៅនេះឡើងផងដែរ។ រាល់ការចូលរួមទាំងអស់របស់លោកអ្នក គឺជាគុណប្រយោជន៏ដ៏ប្រសើរក្នុងការផ្ដល់ចំណេះដឹងអំពីជីវិតសត្វព្រៃនៃប្រទេសយើង។

Illustrated & Designed by SOEURM KAKADA

ឧបត្ថម្ភថវិកាដោយៈ

អនុវត្តគម្រោងដោយៈ

សហការរៀបចំបោះពុម្ពដោយៈ

រូបភាពនិងរចនាដោយៈ
**សឿម កក្កដា**


#១០៩ ផ្លូវ ៩៩ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៦០៤
ទូរសារ : (៨៥៥) ២៣ ២១១ ៦៧២
អ៊ីមែល : kouprey@online.com.kh
វ៉ិបសាយ : www.wildlifealliance.org

#៣៧ B ផ្លូវ ១១៣ សង្កាត់បឹងកេងកង ២
ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ២១៤ ៤០៩
ទូរសារ : (៨៥៥) ២៣ ២២០ ២៤២
អ៊ីមែល : mlup@online.com.kh
វ៉ិបសាយ : www.mlup.org